Khmer/ខ្មែរ

# មគ្គុទេសក៍ ដើម្បីចុះឈ្មោះ និងបោះឆ្នោត

ក្នុងនាមជាពលរដ្ឋអូស្ត្រាលីមានអាយុ១៨ឆ្នាំ ឬលើសពីនេះ លោកអ្នកមានសិទ្ធិ នឹងការទទួលខុសត្រូវក្នុងការចុះឈ្មោះ និងបោះឆ្នោត នៅក្នុងការបោះឆ្នោតសហព័ន្ធ ។ ការចុះឈ្មោះ និងការបោះឆ្នោត គឺជាកាតព្វកិច្ច ។ ប្រសិនបើលោកអ្នកមិនបោះឆ្នោតទេ លោកអ្នកអាចត្រូវពិន័យ ។

## តើយើងអាចជួយយ៉ាងដូចម្ដេច?

គណៈកម្មការរៀបចំការបោះឆ្នោតអូស្ត្រាលី (AEC) ទទួលខុសត្រូវក្នុងការរក្សាកាន់កាប់បញ្ជីបោះឆ្នោតខុម្មិនវែល និងរៀបចំការបោះឆ្នោតសហព័ន្ធ ការបោះឆ្នោតបំពេញកន្លែងនៅទំនេរ និងការធ្វើប្រជាមតិ ។

AEC មិនធ្វើការបោះឆ្នោតរដ្ឋ ដែនដី ឬសាលាសង្កាត់ឡើយ ។ ការបោះឆ្នោតទាំងនេះត្រូវបានចាត់ចែងដោយអាជ្ញាធររៀបចំការបោះឆ្នោតផ្សេងទៀត ។

## ការចុះឈ្មោះបោះឆ្នោត

មុនពេលដែលលោកអ្នកអាចបោះឆ្នោត លោកអ្នកត្រូវតែមានឈ្មោះនៅក្នុងបញ្ជីបោះឆ្នោត ។ បញ្ជីបោះឆ្នោត គឺជាបញ្ជីប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោតទាំងអស់ ដែលបានចុះឈ្មោះបោះឆ្នោតនៅក្នុងការបោះឆ្នោតសហព័ន្ធ និងការធ្វើប្រជាមតិ ។

### តើខ្ញុំអាចចុះឈ្មោះបានឬទេ?

លោកអ្នកត្រូវបានតម្រូវដោយច្បាប់ដើម្បីចុះឈ្មោះ ប្រសិនបើលោកអ្នក ៖

- មានអាយុ១៨ឆ្នាំ ឬលើសពីនេះ
- ជាពលរដ្ឋអូស្ត្រាលី
- បានរស់នៅតាមអាសយដ្ឋានបច្ចុប្បន្នរបស់លោកអ្នកយ៉ាងហោចណាស់មួយខែ ។

ប្រសិនបើលោកអ្នកមានអាយុ១៦ឆ្នាំ ឬ១៧ឆ្នាំ លោកអ្នកអាចចុះឈ្មោះឥឡូវនេះបាន ដូច្នេះនៅពេលលោកអ្នកចូលអាយុ១៨ឆ្នាំ លោកអ្នកនឹងបានត្រៀមខ្លួនរួចរាល់ដើម្បីបោះឆ្នោត ។

### តើខ្ញុំចុះឈ្មោះយ៉ាងដូចម្ដេច?

លោកអ្នកអាចចុះឈ្មោះនៅតាមវ៉ិបសៃថ៍ www.aec.gov.au/enrol ។

លោកអ្នកក៏អាចអញ្ជើញទៅការិយាល័យ AEC ឬការិយាល័យប្រៃសណីយ៍អូស្ត្រាលីណាមួយបានដែរដើម្បីទទួលទម្រង់បែបបទចុះឈ្មោះ ។

### ខ្ញុំមិនប្រាកដថា ខ្ញុំបានចុះឈ្មោះហើយឬនៅ?

លោកអ្នកអាចពិនិត្យមើលការចុះឈ្មោះរបស់លោកអ្នក នៅតាមវ៉ិបសៃថ៍ www.aec.gov.au/check ។

### ប្រសិនបើខ្ញុំផ្លាស់ប្ដូរអាសយដ្ឋាន/ឈ្មោះរបស់ខ្ញុំ តើខ្ញុំត្រូវធ្វើអ្វីខ្លះ?

រាល់ពេលដែលលោកអ្នកផ្លាស់ប្ដូរអាសយដ្ឋាន ឬឈ្មោះរបស់លោកអ្នក លោកអ្នកត្រូវធ្វើបច្ចុប្បន្នភាពការចុះឈ្មោះរបស់លោកអ្នកជាមួយនឹងព័ត៌មានលម្អិតថ្មីរបស់លោកអ្នក ។ លោកអ្នកអាចផ្លាស់ប្ដូរព័ត៌មានលម្អិតរបស់លោកអ្នកតាមអនឡាញ នៅត្រង់វ៉ិបសៃថ៍ www.aec.gov.au ។ លោកអ្នកក៏អាចអញ្ជើញទៅការិយាល័យ AEC ឬការិយាល័យប្រៃសណីយ៍អូស្ត្រាលីណាមួយបានដែរ ដើម្បីទទួលទម្រង់បែបបទចុះឈ្មោះ ។

### ប្រសិនបើខ្ញុំទៅបរទេស តើខ្ញុំគួរធ្វើអ្វីខ្លះ?

ប្រសិនបើលោកអ្នកទៅបរទេសដើម្បីធ្វើការ ឬរស់នៅ លោកអ្នកគួរតែអនុញ្ញាតឱ្យ AEC បានដឹង ។ ប្រសិនបើលោកអ្នកនៅបរទេសនៅពេលការបោះឆ្នោតសហព័ន្ធ ឬការធ្វើប្រជាមតិត្រូវបានប្រកាស លោកអ្នកក៏គួរតែអនុញ្ញាតឱ្យ AEC បានដឹងផងដែរ ។

ប្រសិនបើលោកអ្នកមិនធ្វើដូច្នោះទេ ឈ្មោះរបស់លោកអ្នកអាចត្រូវគេដកចេញពីបញ្ជីបោះឆ្នោត ហើយលោកអ្នកអាចខកខានការបោះឆ្នោតរបស់លោកអ្នក នៅក្នុងការបោះឆ្នោតនាពេលខាងមុខ ។

ព័ត៌មានបន្ថែមអាចរកបាននៅតាមវ៉ិបសៃថ៍ www.aec.gov.au/overseas ។

## ការបោះឆ្នោត

ការបោះឆ្នោតសហព័ន្ធ ត្រូវបានធ្វើឡើងយ៉ាងហោចណាស់រៀងរាល់បីឆ្នាំម្ដង ហើយថ្ងៃបោះឆ្នោតតែងធ្វើឡើងនៅថ្ងៃសៅរ៍ ។ ពេលវេលា និងទីកន្លែងដែលលោកអ្នកបោះឆ្នោត អាស្រ័យទៅលើកន្លែងដែលលោកអ្នកនឹងមានវត្តមាននៅថ្ងៃបោះឆ្នោត ។



AEC Australian Electoral Commission

18_0993/25_2111

អនុញ្ញាតដោយស្នងការរៀបចំការបោះឆ្នោត ទីក្រុង Canberra
Authorised by the Electoral Commissioner, Canberra



សន្លឹកឆ្នោតគំរូ

## នៅថ្ងៃបោះឆ្នោត

លោកអ្នកអាចបោះឆ្នោត នៅកន្លែងបោះឆ្នោតណាមួយនៅក្នុងរដ្ឋ ឬដែនដីរបស់លោកអ្នក ។ កន្លែងបោះឆ្នោតចាប់ផ្តើមបើកនៅម៉ោង៨ព្រឹក និងបិទនៅម៉ោង៦ល្ងាច ។

ប្រសិនបើលោកអ្នកស្ថិតនៅក្នុងរដ្ឋ ឬដែនដីផ្សេងទៀត ហើយលោកអ្នកមិនទាន់បានបោះឆ្នោតនៅឡើយ លោកអ្នកនឹងត្រូវចាំបាច់ត្រូវបោះឆ្នោតនៅមណ្ឌលបោះឆ្នោតអន្តររដ្ឋណាមួយ ។

បញ្ជីកន្លែងបោះឆ្នោត និងមណ្ឌលបោះឆ្នោតអន្តររដ្ឋ នឹងអាចរកបាននៅតាមវិបសៃថ៍ www.aec.gov.au ពីរបីសប្តាហ៍មុនថ្ងៃបោះឆ្នោត ។ ប្រសិនបើលោកអ្នកមិនអាចអញ្ជើញទៅកន្លែងបោះឆ្នោត នៅថ្ងៃបោះឆ្នោតបានទេ លោកអ្នកអាចបោះឆ្នោតបានមុនពេល ។

## ជម្រើសផ្សេងទៀត

លោកអ្នកអាចបោះឆ្នោតបានមុនពេលដោយផ្ទាល់ ឬតាមប្រៃសណីយ៍ ប្រសិនបើនៅថ្ងៃបោះឆ្នោតលោកអ្នក៖

- នៅក្រៅមណ្ឌលបោះឆ្នោតដែលលោកអ្នកបានចុះឈ្មោះដើម្បីបោះឆ្នោត
- ស្ថិតនៅឆ្ងាយជាង៨គីឡូម៉ែត្រពីកន្លែងបោះឆ្នោត
- កំពុងធ្វើដំណើរទៅកាន់ទីឆ្ងាយ
- មិនអាចចាកចេញពីកន្លែងធ្វើការរបស់លោកអ្នកដើម្បីទៅបោះឆ្នោត
- មានជំងឺធ្ងន់ធ្ងរ ចាស់ជរា ឬជិតដល់ពេលសម្រាលកូន (ឬកំពុងថែរក្សានរណាម្នាក់ដែលមានសភាពការណ៍បែបដូចនេះ)
- ជាអ្នកជំងឺនៅមន្ទីរពេទ្យ ហើយមិនអាចបោះឆ្នោតនៅមន្ទីរពេទ្យ
- មានជំនឿសាសនាដែលរារាំងលោកអ្នកមិនឱ្យអញ្ជើញទៅកន្លែងបោះឆ្នោត
- កំពុងជាប់ពន្ធនាគារតិចជាងបីឆ្នាំ ឬត្រូវបានជាប់ឃុំឃាំង
- ជាអ្នកបោះឆ្នោតដោយស្ងៀមស្ងាត់
- មានការភ័យខ្លាចសមហេតុផលចំពោះសុវត្ថិភាពរបស់លោកអ្នក ។

មណ្ឌលបោះឆ្នោតមុនពេល នឹងបើកនៅប៉ុន្មានសប្តាហ៍មុនថ្ងៃបោះឆ្នោត ហើយទីតាំង និងម៉ោងបើក នឹងមានបោះពុម្ពផ្សាយនៅតាមវិបសៃថ៍ www.aec.gov.au ។

ដើម្បីបោះឆ្នោតតាមប្រៃសណីយ៍ លោកអ្នកអាចដាក់ពាក្យសុំតាមអនឡាញ ឬទទួលទម្រង់បែបបទបោះឆ្នោតនៅការិយាល័យ AEC ណាមួយ ។ AEC នឹងផ្ញើចេញនូវកញ្ចប់បោះឆ្នោតតាមប្រៃសណីយ៍របស់លោកអ្នក បន្ទាប់ពីបានបញ្ចប់ការជ្រើសរើសបេក្ខជនបោះឆ្នោតហើយ ។

## ធ្វើឱ្យសន្លឹកឆ្នោតរបស់លោកអ្នកមានតម្លៃ

នៅក្នុងការបោះឆ្នោតសហព័ន្ធ លោកអ្នកកំពុងបោះឆ្នោតដើម្បីជ្រើសរើសមនុស្សដើម្បីជាតំណាងលោកអ្នកនៅក្នុងរដ្ឋសភាពីរនៃសភាអូស្ត្រាលី៖ គឺសភាតំណាងរាស្ត្រ និងព្រឹទ្ធសភា ។

លោកអ្នកនឹងទទួលបានសន្លឹកឆ្នោតពីរ៖

- ពណ៌បៃតង ដើម្បីបោះឆ្នោតជ្រើសរើសអ្នកតំណាងនៃតំបន់មូលដ្ឋានរបស់លោកអ្នក (ឬមណ្ឌលបោះឆ្នោត) នៅក្នុងសភាតំណាងរាស្ត្រ និង
- ពណ៌ស ដើម្បីបោះឆ្នោតឱ្យអ្នកតំណាងរដ្ឋ ឬដែនដីរបស់លោកអ្នកនៅក្នុងព្រឹទ្ធសភា ។

សេចក្តីណែនាំអំពីរបៀបបោះឆ្នោតត្រូវបានបោះពុម្ពលើសន្លឹកឆ្នោត ។ ប្រសិនបើលោកអ្នកធ្វើខុស ឬលោកអ្នកមិនប្រាកដថាត្រូវធ្វើអ្វី សូមគ្រាន់តែសួរមន្ត្រីបោះឆ្នោតប៉ុណ្ណោះដើម្បីទទួលបានជំនួយ ។

## តើចង់ដឹងបន្ថែមទៀតឬ?

លោកអ្នកអាចស្វែងយល់បន្ថែមអំពីប្រព័ន្ធបោះឆ្នោត និងអំពីការចុះឈ្មោះ និងការបោះឆ្នោតនៅតាមវិបសៃថ៍ www.aec.gov.au ។

សេវាកម្មអ្នកបកប្រែភាសាតាមទូរស័ព្ទអាចមានផ្តល់ជូន ។ សម្រាប់ព័ត៌មានអំពីការចុះឈ្មោះ និងការបោះឆ្នោតជាភាសាខ្មែរ សូមទូរស័ព្ទលេខ 1300 720 134 ។

ប្រសិនបើលោកអ្នកជាមនុស្សថ្លង់ ឬមានពិការភាពក្នុងការស្តាប់ ឬនិយាយ សូមទាក់ទងមកយើងតាមរយៈសេវាកម្មជាតិបញ្ជូនបន្ត (NRS)៖

- អ្នកប្រើប្រាស់ TTY សូមទូរស័ព្ទលេខ 13 36 77 ហើយស្នើសុំលេខ 13 23 26 ។
- អ្នកប្រើប្រាស់សេវាកម្មនិយាយ និងស្តាប់ (Speak and Listen) សូមទូរស័ព្ទលេខ 1300 555 727 ហើយសម្រង់លេខ 13 23 26 ។
- អ្នកប្រើប្រាស់បណ្តាញអ៊ីនធើណិតបញ្ជូនបន្ត សូមភ្ជាប់ទៅ NRS បន្ទាប់មកស្នើសុំលេខ 13 23 26 ។



អនុញ្ញាតដោយស្នងការរៀបចំការបោះឆ្នោត ទីក្រុង Canberra
Authorised by the Electoral Commissioner, Canberra